**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ២៣ **អយក.**សណន

# សេចក្តីណែនាំ
# ស្តីពី
# ការប្រើប្រាស់មុខសញ្ញាចំណាយលំអិត
# នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រឹតការ

រាជរដ្ឋាភិបាលបានសម្រេចផ្ទេរការគ្រប់គ្រងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួន៤(កណ្តាល ព្រៃវែង តាកែវ និងកំពង់ចាម) មជ្ឈមណ្ឌលគរុកោសល្យភូមិភាគឥសាននៅខេត្តស្ទឹងត្រែង សាលាគរុកោសល្យនិងវិក្រឹតការចំនួន១៥ និងសាលាអនុវត្តន៍ ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីឆ្នាំ២០២១ តទៅ ដោយអនុលោមតាមស្មារតីនៃលិខិតលេខ៧០៦ សជណ.អវ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ទន្ទឹមនឹងនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍស្ថាប័ននិងលើកកម្ពស់ធនធានមនុស្សប្រកបដោយចីរភាព ហើយស្របនឹងកម្មវិធីកំណែទម្រង់វិស័យអប់រំ ដែលផ្តោតសំខាន់លើការពង្រឹងគុណវុឌ្ឍិគ្រូបង្រៀនជាប់ជាប្រចាំ ដែលជាចលករដ៏សំខាន់ក្នុងការជំរុញឱ្យគ្រឹះស្ថានបណ្តុះបណ្តាលគ្រូមានកាលានុវត្តភាព ព្រមទាំងឆ្លើយតបទៅបរិបទនៃការវិវត្តរបស់សេដ្ឋកិច្ចនិងសង្គមបច្ចុប្បន្ន។ ដូចនេះ ក្រសួង សូមធ្វើការណែនាំបន្ថែមពាក់ព័ន្ធសកម្មភាពនិងមុខសញ្ញាចំណាយលំអិតរបស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគនិងសាលាគរុកោសល្យនិងវិក្រឹតការ ឱ្យកាន់តែមានភាពច្បាស់លាស់និងស្របតាមគោលការណ៍ច្បាប់គតិយុត្តដែលមានស្រាប់ ដើម្បីជាមូលដ្ឋានក្នុងការប្រើប្រាស់ថវិកាឱ្យប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាពខ្ពស់ និងលទ្ធផលនៃការផ្តល់សេវាអាចទទួលយកបាន ដូចខាងក្រោម៖

| ល.រ | សកម្មភាព | លំអិតមុខសញ្ញាចំណាយ |
|---|---|---|
| | **១. គាំទ្រកិច្ចដំណើរការរដ្ឋបាល៖** | |
| ១.១ | **សម្ភារមូលដ្ឋាន (អនុគណនី 60028)** | ▪ គាំទ្រការងាររដ្ឋបាល៖<br>-ក្រដាស ប៊ិក ខ្មៅដៃ ហ្វឺត ទឹកហ្វឺត សៀវភៅ សីមី ទឹកលុប ប៊ិកគូសចំណាំ ក្រូណូ កាវ ស្កុត កន្ត្រៃ បន្ទាត់ ផែនទី ភូគោល កែវពង្រីក ប្រដាប់កិប ប្រដាប់ចោះរន្ធពីរ ឃ្នាប ស្រោមសំបុត្រ ទឹកត្រា ប្រអប់ត្រា ថតចម្លងឯកសារផ្សេងៗ<br>-បោះពុម្ពសៀវភៅ លិខិត ប័ណ្ណសរសើរ បង្កាន់ដៃបង់ប្រាក់ តែមទិដ្ឋាការ ពាក្យស្លោក សញ្ញាបត្រគរុសិស្ស បង់សេវាជីកសំរាមប្រចាំខែ ឯកសារផ្សេងៗ |



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| | | -សៀវភៅសរសេរ សៀវភៅធម៌ សៀវភៅពិន្ទុ បញ្ជីហៅឈ្មោះ គរុសិស្ស គរុនិស្សិត សៀវភៅតាមដានការសិក្សា វចនានុក្រម ប័ណ្ណសម្គាល់ខ្លួន...<br>-ឯកសណ្ឋាន មេដាយ គ្រឿងឥស្សរិយយស<br>-ផ្ទាំងរូបភាពធំៗ ផ្ទាំងពាក្យស្លោក ពាក្យបណ្ដៅ<br>-ដាំស្មៅ ផ្កា និងដើមរុក្ខជាតិផ្សេងៗ<br>-ស្បៀងសម្រាប់រដ្ឋបាលៈ ទឹក តែ កាហ្វេ ស្ករ នំ ផ្លែឈើ...<br>▪ ការងារប្រឡងៈ<br>-ទិញសម្ភារដំណើរការប្រឡងឆមាស ដូចជាៈ ប៊ិក ក្រដាសរ៉ាម ហ្វឹត...<br>-ចំណាយលើការបោះពុម្ព ឬថតចម្លងសន្លឹកកិច្ចការ....<br>-ទិញទឹក នំ ផ្លែឈើ....<br>▪ ចំណាយលើគ្រឿងបរិក្ខារបច្ចេកទេសនិងសង្ហារិមៈ<br>-សម្ភារបច្ចេកទេសព័ត៌មានវិទ្យាៈ ទិញកុំព្យូទ័រ ប្លាស់មែម៉ូរី ទឹកថ្នាំម៉ាស៊ីនថតចម្លង ទឹកថ្នាំម៉ាស៊ីនបោះពុម្ព ម៉ូឌឹមអ៊ីនធើណែត ខ្សែបញ្ជូនរូបភាពឬវីដេអូ ( VGA HDMI ) ...ម៉ាស៊ីនបញ្ចាំងរូបភាព ( LCD Projector ) ម៉ាស៊ីនភ្លើង ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនថតចម្លង ម៉ាស៊ីនស្កេន កាមេរ៉ាសុវត្ថិភាព ម៉ាស៊ីនថតរូប ម៉ាស៊ីនថតវីដេអូ ម៉ាស៊ីនគិតលេខ ដុំពង្រីកសេវា WIFI<br>-សម្ភារប្រើប្រាស់ៈ ទូទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបូមទឹក ម៉ាស៊ីនទឹកក្ដៅ-ត្រជាក់ ម៉ាស៊ីនបូមធូលី ម៉ាស៊ីនកាត់ស្មៅ បំពង់ពន្លត់អគ្គីភ័យ អាគុយ ឧបករណ៍បំពងសំឡេង (អំភ្លី មេក្រូ ធុងបាស) អំពូលភ្លើង អំពូលសូឡា កង្ហារ ទូរស័ព្ទលើតុ ព្រីភ្លើង ថ្មពិល មែម៉ូរី កាសែតថតសំឡេង ឌីស ឧបករណ៍ថតសំឡេង សោ ញញួរ ចបរណារ បង្គី វាំងនន តង់កៅស៊ូ ទង់ជាតិ ស៊ុមរូបថត កម្រាលតុ ជូផ្កា ព្រះឆាយាលក្ខណ៍ កញ្ចក់ ទុយោបាញ់ទឹក សោទ្វារ គន្លឹះទ្វារ គន្លឹះបង្អួច ត្រចៀកទ្វារ ត្រចៀកបង្អួច<br>-គ្រឿងសង្ហារិមៈ តុ ទូ ធ្នើរ កៅអីសិស្ស/គ្រូ ក្ដារខៀន។ល។<br>▪ ចំណាយលើសេវាដូចខាងក្រោមៈ<br>-ទិញទឹក បញ្ចូលអាគុយ បូមលូ បង់ថ្លៃសេវាទូរស័ព្ទ សេវាសំរាម សេវាអ៊ីនធើណែត<br>-ទិញសៀវភៅមូលប្បទានប័ត្រនិងបង់ថ្លៃសេវាធនាគារ<br>-តបណ្ដាញថ្មីដូចជាៈ ទឹក អគ្គិសនី កុំព្យូទ័រ អ៊ីនធឺណែត។ល។<br>-ចំណាយសោហ៊ុយធ្វើដំណើរៈ ថ្លៃម៉ូតូឌុប ឬរថយន្តឈ្នួល សាំងម៉ូតូសម្រាប់ទំនាក់ទំនងការងារជាមួយក្រសួងនិងអង្គភាពពាក់ព័ន្ធផ្សេងៗ |

| | | |
|---|---|---|
| | | -ការដឹកជញ្ជូនៈ ថ្លៃផ្ញើឯកសារផ្សេងៗ និងចំណាយលើមធ្យោបាយដឹកជញ្ជូនសម្ភារទំនិញ(គេះទំនិញ សម្ភារការិយាល័យ សម្ភាបរិក្ខារបច្ចេកទេស សង្ហារិម) ។ល។<br>-ចំណាយផ្សេងៗ ដែលបម្រើឱ្យសកម្មភាពរងខាងលើ។ |
| ១.២ | ការថែទាំនិងជួសជុលយានយន្ត(អនុគណនី 61058) | -ចំណាយដែលពាក់ព័ន្ធនឹងការងារថែទាំនិងជួសជុលគ្រប់ប្រភេទលើយានយន្ត (កង់ ម៉ូតូ រថយន្ត...) ដែលជាទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាព (សោហ៊ុយយានដ្ឋាន)។ល។ |
| ១.៣ | ការថែទាំ និងជួសជុលតូចតាច(អនុគណនី 61058) | ▪ ចំណាយលើការថែទាំនិងជួសជុលៈ<br>-ជួសជុលអគារ ទីចាត់ការ បណ្ណាល័យ ថ្នាក់រៀន ដំបូល បង្គន់ អនាម័យនិងទឹកស្អាត ខ្លោងទ្វារ របង ឃ្លាំង ទីលានកីឡា លាបថ្នាំរបង/អគារ សួនច្បារ ខឿនទង់ជាតិ ចំណតយានយន្ត រូបសំណាកផ្សេងៗ<br>-ការចាក់ដី (បំពេញគ្រហុក បំពេញដីស្រះ ត្រពាំង) ស្ពារ(ស្រះ ត្រពាំង អណ្តូង) ចាក់សាប ក្រាលការ៉ូ<br>-ទិញខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ លូ បង់ រទេះរុញ ស្លាកសញ្ញា<br>-ជួសជុល តុ កៅអី ទូ ទ្វារ បង្អួច ផ្ទើរ។ល។ |
| ១.៤ | សម្ភារសម្អាតនិងអនាម័យ (អនុគណនី 60058) | -ចំណាយលើការទិញសម្ភារសម្អាតនិងអនាម័យដូចជាៈ អូសាវែល សាប៊ូ សាប៊ូដុំ សាប៊ូលាងចាន សាប៊ូលាងបន្ទប់ទឹកនិងបង្គន់ សាប៊ូលាងការ៉ូ ទឹកលាងកញ្ចក់ ក្រដាសអនាម័យ ក្រដាសជូតមាត់ ធុងសំរាម ឡដុតសំរាម ទឹកក្រអូបបាញ់បន្ទប់ ច្រាសដុសបន្ទប់ទឹក ច្រាសដុសការ៉ូ អំបោសបោសទឹក អំបោសជាងដូង ក្រណាត់ជូតជើង ប្រដាប់ជូតការ៉ូ កន្សែងជូតដៃ ថ្នាំបាញ់មូស ដង្កៀបចាប់សំរាម ថង់ប្លាស្ទិក ចប បង្គី រនាស់ដៃ កាំបិតកាប់ផ្កាព្រៃ<br>-ចំណាយលើការទិញសម្ភារនិងបរិក្ខារសុខភាព (អាកុល សាប៊ូលាងដៃ ឧបករណ៍វាស់កម្តៅ ម៉ាស់ ដែលលាងដៃ ទឹកសម្លាប់មេរោគ កន្ត្រៃ បង់រុំរបួស ថ្នាំលាងរបួស សំឡី ថ្នាំពេទ្យ សម្ភារព្យាបាល សម្ភារសង្គ្រោះបឋម។ល។ |
| ១.៥ | ការថែទាំនិងជួសជុលបរិក្ខារបច្ចេកទេស (អនុគណនី 61058) | -ចំណាយលើការថែទាំនិងជួសជុលបរិក្ខារបច្ចេកទេសដូចជាៈ កុំព្យូទ័រ ម៉ាស៊ីនបោះពុម្ព ម៉ាស៊ីនថតចម្លង ម៉ាស៊ីនស្កេន ម៉ាស៊ីនថតរូប ម៉ាស៊ីនថតវីដេអូ កាមេរ៉ាសុវត្ថិភាព ម៉ាស៊ីនភ្លើង ម៉ាស៊ីនបញ្ចាំងរូបភាព(LCD Projector) ម៉ាស៊ីនបូមធូលី រចនាសម្ព័ន្ធបណ្តាញព័ត៌មានវិទ្យា(Network Infrastructure) ទូទឹកកក ម៉ាស៊ីនត្រជាក់ ម៉ាស៊ីនបូមទឹក ម៉ាស៊ីនទឹកក្តៅត្រជាក់ ម៉ាស៊ីនកាត់ស្មៅ ឧបករណ៍បំពងសំឡេង ទូរស័ព្ទលើតុ ឧបករណ៍ថតសំឡេង អាគុយ កង្ហារ |

| | | |
|---|---|---|
| | | -ឧបករណ៍ឬសម្ភារ អគ្គិសនី ទឹក ទូរស័ព្ទ និងអ៊ីនធើណែត<br>-បណ្តាញអគ្គិសនី ទឹកស្អាត លូ ទូរស័ព្ទ និងអ៊ីនធើណែត។ល។ |
| ១.៦ | ប្រេងឥន្ធនៈ (អនុគណនី 60028) | ចំណាយលើការទិញប្រេងឥន្ធនៈ និងប្រេងរំអិលសម្រាប់ថែទាំនិងដំណើរការយានយន្តនិងគ្រឿងម៉ាស៊ីនផ្សេងៗដូចជា៖ប្រេងលាយ ប្រេងម៉ាស៊ីន ប្រេងម៉ាស៊ូត ប្រេងសាំង ប្រេងកាត ដែលបម្រើឱ្យការងាររដ្ឋបាលនិងសកម្មភាពការងាររបស់អង្គភាព។ |
| ១.៧ | ប្រាក់បេសកកម្ម(អនុគណនី 61108) | -ចំណាយលើសោហ៊ុយទំនាក់ទំនងសាធារណៈដូចជា៖ យកសំណុំឯកសារផ្សេងៗ ជូនក្រសួងអប់រំ យុវជន និងកីឡា និងអង្គភាពពាក់ព័ន្ធ<br>-ចូលរួមប្រជុំ សិក្ខាសាលា និងសកម្មភាពផ្សេងៗ<br>-ពិនិត្យតាមដានលើការរៀននិងបង្រៀនរបស់គរុសិស្ស គរុនិស្សិត។ |
| ១.៨ | ចំណាយផ្សេងៗ(អនុគណនី 60028) | ចំណាយលើសកម្មភាពផ្សេងៗក្រៅពីមុខសញ្ញាចំណាយខាងលើ។ |
| ២. ពង្រឹងប្រសិទ្ធភាពការបង្រៀននិងរៀន៖ | | |
| ២.១ | សម្ភារនិងសកម្មភាពបង្រៀននិងរៀន(អនុគណនី 60058) | -ចំណាយទិញប៊ិក ខ្មៅដៃ ហ្វឺត គូល័រ សៀវភៅ ក្រដាស ក្រដាសពណ៌ ក្រដាសកាតុង សឺមី ស្កុត កាវ កន្ត្រៃ ដែកឈាន បន្ទាត់ បន្ទាត់កែង ផែនទី ភូគោល តារាងខួបគីមី ម៉ាស៊ីនគិតលេខមុខងារខ្ពស់ អក្សរចល័ត លេខចល័ត ដូមីណូ ផ្លាកសញ្ញាចរាចរណ៍ ក្តារខៀនសំពត់ ប័ណ្ណពាក្យ រូបភាព ក្រណាត់ ម្ជុល អំបោះ អំពូលឈើ កុងប្លាកេ ដែកគោល ដក់ ថ្នាំលាបឈើ ក្រដាសខាត់ កន្ត្រៃសោ បាល់ សំណាញ់ គ្រាប់សី បោះពុម្ព និងថតចម្លង សម្ភារឧបទេសផ្សេងៗ<br>-សម្ភារផ្ទះបាយ៖ គ្រឿងទេស បន្លែ ត្រី សាច់<br>-គេហកិច្ច៖ អំបោស ក្រណាត់ ម្ជុល ម៉ាស៊ីនដេរ ម៉ាស៊ីផុង កន្ត្រៃឡាម គ្រឿងបន្លាស់(ម៉ាស៊ីនដេរ និងផុង) និងសម្ភារផ្សេងៗ<br>-ចំណាយទិញស៊ីឌី ប្លាស់មែម៉ូរី កាសែតថតសំឡេង ឧបករណ៍ថតសំឡេង ទូរទស្សន៍ ម៉ាស៊ីនបញ្ចាំងរូបភាព(LCD Projector) ម៉ាស៊ីនថតវីដេអូ និងឧបករណ៍ផ្សេងៗ<br>-ចំណាយទិញសម្ភារពិសោធន៍ដូចជា៖ វ៉ែនតា សំឡី កែវ កែវបាឡុង ថ្មពិល អាកុល ទែម៉ូម៉ែត្រ អាស៊ីត អាគុយ សារធាតុគីមី រូប ជីវៈ វត្ថុធាតុដើម សម្លៀកបំពាក់ និងគ្រឿងសុវត្ថិភាព សម្ភារប្រតិបត្តិ និងសម្ភារសម្រាប់ពិសោធន៍ផ្សេងៗទៀតតាមមុខវិជ្ជា(រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា) មុខជំនាញ និងគ្រប់កម្រិតសិក្សា<br>-ការចំណាយទិញសៀវភៅរឿងនិទាន ប្រលោមលោក រឿងខ្លី សៀវភៅរូបភាព វចនានុក្រម សៀវភៅប្រវត្តិសាស្ត្រ សៀវភៅកំណាព្យ |

| | | |
|---|---|---|
| | | សៀវភៅគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា សៀវភៅវិទ្យាសាស្ត្រ សៀវភៅលំហាត់ និងឯកសារអំណាន។ល។ |
| ២.២ | សកម្មភាពអប់រំសីលធម៌និងមនសិការវិជ្ជាជីវៈ (អនុគណនី 60058) | -ចំណាយលើការទិញសៀវភៅអប់រំចិត្ត សៀវភៅធម៌ ស្លាដក ធ្វើបដាក្នុងពិធីបុណ្យផ្សេងៗ<br>-ធ្វើស្លាកសញ្ញាឬរូបភាពអប់រំពីវិជ្ជាជីវៈគ្រូ ច្បាប់ចរាចរណ៍ គ្រឿងញៀន ការជួញដូរមនុស្ស ការគោរពសិទ្ធិកុមារ/ស្ត្រី...<br>-ចំណាយលើការរៀបចំកម្មវិធីសូត្រមន្ត ពិធីចូលឆ្នាំខ្មែរ បុណ្យកាន់បិណ្ឌ ការប្រារព្ធទិវាផ្សេងៗ<br>-ចំណាយលើការទិញភេសជ្ជៈ និងអាហារសម្រន់ក្នុងកម្មវិធី សំណេះសំណាល ឬជួបជាមួយវាគ្មិនកិត្តិយស។ល។ |
| ២.៣ | សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ(អនុគណនី 60058) | -ចំណាយលើការកសាង និងការប្រើប្រាស់សម្ភារឧបទេស (តារាងទាំង៩ ការតុបតែងថ្នាក់រៀន)<br>-ចំណាយលើការទិញក្រដាសរ៉ាម ក្រដាសរ៉ាមពណ៌ ក្រដាសផ្ទាំងធំ ក្រដាសកាតុង ស្កុត កន្ត្រៃ កាវ...<br>-ចំណាយលើការទិញសម្ភារពិសោធន៍ផ្សេងៗ សម្ភារឧបទេសតាមមុខវិជ្ជា<br>-ចំណាយលើការធ្វើថ្នាក់និទស្សន៍ (ថតចម្លងកិច្ចតែងការ ក្រដាសកិច្ចការ ព្រឹត្តបត្រសង្កេត ភេសជ្ជៈ និងអាហារសម្រន់។ |
| ២.៤ | ប្រជុំបច្ចេកទេស(អនុគណនី 60028) | -ចំណាយលើការថតចម្លងឯកសារ<br>-ចំណាយលើការទិញភេសជ្ជៈ និងអាហារសម្រន់ក្នុងពេលប្រជុំ<br>-ចំណាយលើសម្ភារឧបទេសរៀននិងបង្រៀន។ល។ |
| ២.៥ | សកម្មភាពពលកម្មផលិត (អនុគណនី 60058) | -ចំណាយលើការទិញ និងការផលិតសម្ភាររៀននិងបង្រៀន រោងជាង (ឈើ ស៊ីម៉ងត៍ ចប បង្គី ប៉ែល ញញួរ រណារ ពូថៅ កាំបិត ដែកខួង ផ្លែស្វាន ម៉ែត្រ ដែកឈូស ដែកឆាប ពន្លាក ដង្កាប់ ដែកដាប់ ក្រដាសខាត់ សោមួលគ្រប់ប្រភេទ និងឧបករណ៍ឬប្រដាប់ប្រដាផ្សេងៗ)<br>-ចំណាយលើការទិញក្រដាសកាតុង ក្រដាសពណ៌ កាវ ស្កុតថ្លា កន្ត្រៃតូចធំ គូល័រពណ៌<br>-ផ្នែកកសិកម្ម៖ ចប បង្គី ប៉ែល ពូជបន្លែ ដី ធុង ពូជសត្វ រៀបចំស្រះចិញ្ចឹមត្រី រោងចិញ្ចឹមសត្វ ចំណីត្រី ចំណីសត្វ<br>-ផ្នែករោងជាង៖ ឈើ ស៊ីម៉ងត៍ ខ្សាច់ ថ្ម ញញួរ រណារ ពូថៅ កាំបិត ដែកខួង ផ្លែស្វាន ម៉ែត្រ ដែកឈូស ដែកឆាប ពន្លាក ដង្កាប់ ដែកដាប់ ក្រដាសខាត់ សោមួលគ្រប់ប្រភេទ និងឧបករណ៍ឬប្រដាប់ប្រដាផ្សេងៗ |

| | | |
|---|---|---|
| | | -ចំណាយលើការទិញគ្រាប់ធញ្ញជាតិ គ្រាប់ពូជ កូនឈើ និងសម្ភារកសិកម្មផ្សេងៗ<br>-ចំណាយលើការចិញ្ចឹមសត្វ (ទិញពូជសត្វ ចំណី សម្ភារផ្សេងៗ)។ |
| ២.៦ | សកម្មភាពសិល្បៈនិងកីឡា (អនុគណនី 60058) | -ចំណាយលើការទិញឧបករណ៍ភ្លេងបុរាណ (ស្គរ នេនាត ខ្លុយ ទ្រ឵ឃឹមតូច ឃឹមធំ ស្រឡៃ គងតូច គងធំ ...) ឧបករណ៍តន្ត្រីសម័យ សំលៀកបំពាក់របាំ សម្ភារសម្រាប់គំនូរ សូនរូប គ្រឿងតុបតែងកាយ<br>-ចំណាយលើការជួលគ្រូបង្វឹកផ្នែកសិល្បៈ របាំ កីឡា។<br>-ចំណាយលើការទិញសម្ភារកីឡា (បាល់ទះ បាល់ទាត់ បាល់បោះ សំណាញ់ សម្លៀកបំពាក់ ស្រោមជើង ស្រោមដៃ កញ្ចែ...)<br>-ចំណាយលើការអប់រំកាយ (ខ្សែពួរ ដុំដែក ថាសចោល .....)<br>-ចំណាយលើការហ្វឹកហាត់ សម្តែង រង្វាន់ ព្រមទាំងការប្រកួតកីឡាក្នុងកម្មវិធីផ្សេងៗ។ |
| ២.៧ | ចុះពិនិត្យតាមដានគ្រូនិងសកម្មភាពស្រាវជ្រាវ (អនុគណនី 61108) | -ចំណាយលើការទិញសម្ភារឧបទេស ថតចម្លងឯកសារវាយតម្លៃ កម្រងសំណួរ ឯកសារផ្សេងៗ<br>-ចំណាយលើសេវាអ៊ីនធើណែត និងការជួលសេវាផ្សេងៗសម្រាប់ផ្គត់ផ្គង់ដល់ការស្រាវជ្រាវ<br>-ចំណាយលើសោហ៊ុយធ្វើដំណើរ ស្នាក់នៅ និងហូបចុក<br>-ចំណាយលើការជួលរថយន្ត ម៉ូតូ និងមធ្យោបាយធ្វើដំណើរផ្សេងៗ។ |
| ២.៨ | ដឹកនាំគរុសិស្សចុះកម្មសិក្សា (អនុគណនី 61108) | -ចំណាយលើភេសជ្ជៈនិងអាហារសម្រន់ក្នុងការប្រជុំគណៈកម្មការមុនពេលចុះកម្មសិក្សា<br>-ចំណាយលើការថតចម្លងឯកសារចុះកម្មសិក្សា<br>-ចំណាយលើការទិញឬជួលសម្ភារចុះកម្មសិក្សាសម្រាប់គរុសិស្ស<br>-ចំណាយលើការទិញសម្ភារឧបទេសរៀននិងបង្រៀន<br>-ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៤០ ០០០រៀល ក្នុងម្នាក់ក្នុងមួយថ្ងៃ សម្រាប់គ្រូដឹកនាំសម្រាប់ចុះពិនិត្យតាមដានគរុសិស្ស ដែលស្ថិតក្នុងរង្វង់ដែនដីក្រុង ស្រុករបស់ខ្លួន<br>-ចំណាយលើការជួលរថយន្ត ម៉ូតូ និងមធ្យោបាយធ្វើដំណើរផ្សេងៗ។ |
| ២.៩ | ពិនិត្យតាមដានកម្មវិធីសិក្សាគរុកោសល្យ (អនុគណនី 61108) | -ចំណាយលើភេសជ្ជៈ និងអាហារសម្រន់ដល់ការប្រជុំគណៈកម្មការមុនចុះកម្មសិក្សាគរុកោសល្យ<br>-ចំណាយលើការថតចម្លងឯកសារកម្មសិក្សា កម្រងសំណួរ<br>-ចំណាយលើការទិញឬជួលសម្ភារចុះកម្មសិក្សាសម្រាប់គរុសិស្ស<br>-ផ្តល់ប្រាក់ឧបត្ថម្ភចំនួន ៤០ ០០០រៀល ក្នុងម្នាក់ក្នុងមួយថ្ងៃ សម្រាប់ការចុះពិនិត្យតាមដានគ្រូ ដែលស្ថិតក្នុងរង្វង់ដែនដីក្រុង ស្រុករបស់ខ្លួន។ |

| | | |
|---|---|---|
| ២.១០ | ទស្សនកិច្ចសិក្សា<br>(អនុគណនី 61108) | -ចំណាយលើសោហ៊ុយ ស្នាក់នៅ និងហូបចុក របស់គ្រូដឹកនាំ<br>-ចំណាយលើការជួលរថយន្ត ម៉ូតូ និងមធ្យោបាយធ្វើដំណើរផ្សេងៗ<br>-ចំណាយលើការទិញសម្ភារឧបទេសរៀននិងបង្រៀន<br>-ចំណាយលើការរៀបចំបង្ហា បោះពុម្ពឯកសារ<br>-ចំណាយផ្សេងៗ។ |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី** នាយកឬនាយិកានៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការ ជ្រាបនិងចាត់ចែងអនុវត្តន៍ឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ៣រោច ៥កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

-គ្រប់អគ្គនាយកដ្ឋាននិងអគ្គាធិការដ្ឋាន

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

" ដើម្បីជ្រាបជាព័ត៌មាន "

-កាលប្បវត្តិ

-ឯកសារនាយកដ្ឋានហិរញ្ញវត្ថុ